មាតិកា

I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

២១-៥-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៥១២/៤៣៦ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ មន្ត្រីរាជការ ចំនួន ០៦ រូប ៣៨០១

២១-៥-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៥១២/៤៣៧ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍនី ចំពោះ នាយទាហានជាន់ខ្ពស់ ចំនួន ១០ រូប ៣៨០២

២១-៥-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៥១២/៤៣៩ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ថ្នាក់ដឹកនាំ និង មន្ត្រីរាជការ នៃខេត្តព្រះវិហារ ចំនួន ១០ រូប ៣៨០៣

២១-៥-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៥១២/៤៤០ ស្តីពី ការតម្លើងឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ត្រី ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ចំនួន ០៧ រូប ៣៨០៤

២១-៥-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៥១២/៤៤១ ស្តីពី ការតែងតាំងមុខតំណែង ឯកឧត្តម ឧត្តមសេនីយ៍ទោ **ថោង ខរលក្ខណ៍** ជាទីប្រឹក្សា ឯកឧត្តម ស **ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន និង ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ឯក ជូនឯកឧត្តម ឧត្តមសេនីយ៍ទោ **ថោង ខរលក្ខណ៍** នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ៣៨០៥

២១-៥-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៥១២/៤៤២ ស្តីពី ការតែងតាំងឯកឧត្តម ចំនួន ០២ រូប ជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិវាយតម្លៃ ទីក្រុងស្អាត មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ៣៨០៦

២១-៥-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៥១២/៤៤៣ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ចំនួន ២៥ រូប ៣៨០៧

២១-៥-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៥១២/៤៤៤ ស្តីពី ការតែងតាំងឯកឧត្តម ចំនួន ០៤ រូប ជាទីប្រឹក្សារដ្ឋមន្ត្រីក្រសួងទេសចរណ៍ មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ៣៨០៩

២១-៥-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៥១២/៤៤៥ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ចំពោះ សប្បុរសជន ចំនួន ០២ រូប ៣៨១០

២១-៥-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៥១២/៤៤៦ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំពោះ សប្បុរសជន ចំនួន ០២ រូប ៣៨១១

២១-៥-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៥១២/៤៤៧ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ ព្រះសង្ឃ និង សប្បុរសជន ចំនួន ០៤ រូប ៣៨១២

២១-៥-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៥១២/៤៤៨ ស្តីពី ការតម្លើងថ្នាក់ ក្នុងឋានន្តរស័ក្តិ ឧត្តមមន្ត្រី ជូនមន្ត្រីរាជការ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងព្រះបរមរាជវាំង ចំនួន ០៧ រូប ៣៨១៣

២១-៥-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៥១២/៤៤៩ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតូបការ ចំពោះ ថ្នាក់ដឹកនាំ ចំនួន ០៣ រូប នៅខេត្តប៉ៃលិន ៣៨១៤

II~រាជរដ្ឋាភិបាល

១~អនុក្រឹត្យ

១៨-៥-២០១២ -អនុក្រឹត្យលេខ ៧៣ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ផ្ទៃដី ទំហំ ៥.៩១៤ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកសន្ទុក ខេត្តកំពង់ធំ ៣៨១៥

២២-៥-២០១២ -អនុក្រឹត្យលេខ ៧៤ អនក្រ.បក ស្តីពី ការដាក់ឱ្យប្រើប្រាស់នីតិវិធីរួមបច្ចុប្បន្នកម្ម សម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍ ៣៨១៨

១៨-៥-២០១២ -អនុក្រឹត្យលេខ ៥៨៦ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៣៨២០

១៨-៥-២០១២ -អនុក្រឹត្យលេខ ៥៨៧ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៣៨២១

១៨-៥-២០១២ -អនុក្រឹត្យលេខ ៥៨៨ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៣៨២២

១៨-៥-២០១២ -អនុក្រឹត្យលេខ ៥៨៩ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៣៨២៣

២១-៥-២០១២ -អនុក្រឹត្យលេខ ៥៩០ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៣៨២៤

២១-៥-២០១២ -អនុក្រឹត្យលេខ ៥៩១ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៣៨២៥

២១-៥-២០១២ -អនុក្រឹត្យលេខ ៥៩២ អនក្រ.តត ស្តីពី ការតែងតាំងមុខងារ នាយទាហាន ៣៨២៧

២១-៥-២០១២ -អនុក្រឹត្យលេខ ៥៩៣ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៣៨២៨

២១-៥-២០១២ -អនុក្រឹត្យលេខ ៥៩៤ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៣៨២៩

២១-៥-២០១២ -អនុក្រឹត្យលេខ ៥៩៥ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៣៨៣០

២១-៥-២០១២ -អនុក្រឹត្យលេខ ៥៩៦ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៣៨៣១

២១-៥-២០១២ -អនុក្រឹត្យលេខ ៥៩៧ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៣៨៣២

២១-៥-២០១២ -អនុក្រឹត្យលេខ ៥៩៨ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៣៨៣៣

២១-៥-២០១២ -អនុក្រឹត្យលេខ ៥៩៩ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៣៨៣៤

២_សេចក្តីណែនាំ

២៥-៥-២០១២ -សេចក្តីណែនាំលេខ ០១ សណន ស្តីពី ការផ្អាកមិនឱ្យលក់ដូ និង ពិសារគ្រឿងស្រវឹង មួយថ្ងៃ មុនថ្ងៃបោះឆ្នោត និង ថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី ៣ ថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ ២០១២ ៣៨៣៥

III_ការងារបណ្តាក្រសួង

ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

០១-៣-២០១១ -លិខិតបញ្ជាក់លេខ ១០៨៥ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ចំរើន រតនៈ** ៣៨៣៧

០១-៣-២០១១ -លិខិតបញ្ជាក់លេខ ១០៨៧ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **រតនៈ ទេពី គ្រែនស្តុំត** ៣៨៣៩

០១-៣-២០១១ -លិខិតបញ្ជាក់លេខ ១០៨៨ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឆួន មិញ ដាត គ្រុឌិង** ៣៨៤១

០១-៣-២០១១ -លិខិតបញ្ជាក់លេខ ១០៩៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អិម & ខេ អ៊ីមផត អេន អិចផត** ៣៨៤៣

០២-៣-២០១១ -លិខិតបញ្ជាក់លេខ ១១០០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ីធីអេចធី អេនជីនារីង** ៣៨៤៥

០២-៣-២០១១ -លិខិតបញ្ជាក់លេខ ១១០១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ធីអិមម៉ាយ អ៊ីមផត អិចផត** ៣៨៤៧

០២-៣-២០១១ -លិខិតបញ្ជាក់លេខ ១១០៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ៊ុង ជីង គួយ** ៣៨៤៩

០២-៣-២០១១ -លិខិតបញ្ជាក់លេខ ១១០៤ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស្ទឺរ៉ូលីណា** ៣៨៥១

ព្រះរាជក្រឹត្យ

នស/រកត/០៥១២/៤៣៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

មន្ត្រីរាជការ ចំនួន ០៦រូប ដែលមានស្នាដៃល្អ ក្នុងការចូលរួមសាងសង់កំណាត់ផ្លូវជាតិលេខ៥៧
ពីខេត្តបាត់ដំបង ដល់ខេត្តប៉ៃលិន(ព្រំប្រទល់កម្ពុជា-ថៃ) សម្រេចបានលទ្ធផលល្អប្រសើរ

នូវ

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :
- ឯកឧត្តម គី លីជា

ខ-គ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិមុនីវង្សកុសុមៈនារីរ័ត្ន ថ្នាក់ មហាសេរីវឌ្ឍន៍ :
១- ឯកឧត្តម ខាន់ ម៉ាណោរ
២- លោក ស៊ុន សុគន់

គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :
- លោក អ៊ីន គីម

ឃ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា :
១- លោក ត្រី ម៉ុង
២- លោក សឿម នុភាព

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ: ៤១៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១២
អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល
សិយ សុខា

៣៩២.១៧០៥.៤៤១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១២

ព្រះរាជក្រឹត្យ

នស/រកត/០៥១២/៤៣៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

នាយទាហានជាន់ខ្ពស់ ចំនួន១០រូប ចំណុះយោធភូមិភាគទី៥
មានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិ កន្លងមក

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :

១-	ឧត្តមសេនីយ៍ទោ	ឈឿន	សារិទ្ធ	អត្តលេខ ០០០១៥៨
២-	ឧត្តមសេនីយ៍ទោ	ពេជ្រ	សាង	អត្តលេខ ០០០១៨០
៣-	ឧត្តមសេនីយ៍ទោ	ហ៊ាន	ហ៊ឹម	អត្តលេខ ០០០៣៩៦
៤-	ឧត្តមសេនីយ៍ទោ	កែវ	ពិសិដ្ឋ	អត្តលេខ ០០០២៩០
៥-	ឧត្តមសេនីយ៍ទោ	ញ៉ែម	គង់	អត្តលេខ ០០៣៨១៤
៦-	ឧត្តមសេនីយ៍ទោ	ងឹង	ផុន	អត្តលេខ ០០៣៨១៨
៧-	ឧត្តមសេនីយ៍ទោ	ស៊ុំ	សាម៉េត	អត្តលេខ ០០៣៨០៧
៨-	ឧត្តមសេនីយ៍ត្រី	អ៊ុក	ឆា	អត្តលេខ ០០១០១៨
៩-	ឧត្តមសេនីយ៍ត្រី	ព្រាប	ឧត្តម	អត្តលេខ ០០១១៨២
១០-	ឧត្តមសេនីយ៍ត្រី	ឆន់	ម៉ុនអ៊ី	អត្តលេខ ០០១០៥០

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ: ៥១៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី រាជរដ្ឋាភិបាល
សយ សុខា

៣រល.១២០៥.៤៤២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១២

ព្រះរាជក្រឹត្យ

នស/រកត/០៥១២/៤៣៩

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃខេត្តព្រះវិហារ ចំនួន១០រូប
មានស្នាដៃល្អក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិ កន្លងមក

នូវ

ក-គ្រឿងឥស្សរិយយស សម្ដេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិមុនីវង្ស កុសុមៈនារីរ័ត្ន ថ្នាក់ មហាសេរីវឌ្ឍន៍ :

១-ឯកឧត្តម ឡុង សុវណ្ណ
២-ឯកឧត្តម ណែម ទាំ

ខ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ :

១-លោក ស៊ុយ សេរិទ្ធ
២-លោក ស សំអុល
៣-លោក អ៊ុន ចាន់ដា
៤-លោក ខូយ យុនហ៊ី
៥-លោក ចាន ឆន

គ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ :

១-លោក មុត តិសិទ្ធនា
២-លោក ជា ពិសិដ្ឋ
៣-លោក ឈុន យូ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ:៤៧៧/ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្ដីការគណៈរដ្ឋមន្ត្រី
[illegible] សុខា

[illegible].១២០៥.៤៤៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១២

ព្រះរាជក្រឹត្យ

យើង

នស/រកត/០៥១២/៤៤០

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៥០១ / ១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ ៖ ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម ៖

១- លោកវរសេនីយ៍ឯក **ប៉ុល សុខនាង** អត្តលេខ ០៦១៣១
២- លោកវរសេនីយ៍ឯក **វ៉ាន់ ចន្ទី** អត្តលេខ ០៥១០៨
៣- លោកវរសេនីយ៍ឯក **ភឿន សុភត្រា** អត្តលេខ ៦៨៣៦១
៤- លោកវរសេនីយ៍ឯក **ទួន ធី** អត្តលេខ ០៨៨៧៨
៥- លោកវរសេនីយ៍ឯក **សុខ សំសោភ័ណ** អត្តលេខ ០១១៧៣
៦- លោកវរសេនីយ៍ឯក **សេង អ៊ីន** អត្តលេខ ០៨១៦
៧- លោកវរសេនីយ៍ឯក **សំ ដារ៉ា** អត្តលេខ ០៧៨៨៨ ។

មាត្រា ២ ៖ បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ ៖ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ ៖ ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ៕

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

តាកស.១២០៥.៤៤៥

លេខ ... ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០១២
... សុខា

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១២

ព្រះរាជក្រឹត្យ

នស/រកត/០៥១២/៤៤១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងមុខតំណែង ឯកឧត្តម ឧត្តមសេនីយ៍ទោ **ថោង ចរលក្ខណ៍** អត្តលេខ ០៣៨៩ ជាទីប្រឹក្សា ឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២ : ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូន ឯកឧត្តម ឧត្តមសេនីយ៍ទោ **ថោង ចរលក្ខណ៍** អត្តលេខ ០៣៨៩ នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ។

មាត្រា ៣ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ចរណ.១២០៥.៤៤៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១២

លេខ: ៤២៩ ច.ល

សេចក្តីថតចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ២០១២

អគ្គលេខាធិការរងអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

[illegible] សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៥១២/៤៤៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១.- ត្រូវបានតែងតាំង ៖

១- ឯកឧត្តម អាំង សុវណ្ណរ័ត្ន ជាអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិវាយតំលៃទីក្រុងស្អាត មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារ បច្ចុប្បន្ន

២- ឯកឧត្តម សុខ សង្ហារ ជាអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិវាយតំលៃទីក្រុងស្អាត មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២.- សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣.- ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចរកា.១២០៥.៤៤៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១២

លេខ: ៤០៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ២០១២
[illegible] ទីស្តីការគណៈរដ្ឋមន្ត្រី [illegible]
សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៥១២/៤៤៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានដំឡើងឋានន្តរស័ក្តិជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ៖

ក- ថ្នាក់ឧត្តមសេនីយ៍ឯក

១- លោកឧត្តមសេនីយ៍ទោ **សៅ ធីរៈឧុយ** អត្តលេខ ០៥៨៨
២- លោកឧត្តមសេនីយ៍ទោ **ឈួន សុវណ្ណ** អត្តលេខ ០៧៤៧៩ ។

ខ- ថ្នាក់ឧត្តមសេនីយ៍ទោ

១- លោកឧត្តមសេនីយ៍ត្រី **កែវ ឧុរ្ឆាជា** អត្តលេខ ០៨០៥
២- លោកឧត្តមសេនីយ៍ត្រី **រស់ សារិទ្ធ** អត្តលេខ ០៨០១
៣- លោកឧត្តមសេនីយ៍ត្រី **គោរត សាម៉ុន** អត្តលេខ ០៣៧៦៨
៤- លោកឧត្តមសេនីយ៍ត្រី **អ៊ុំ សំបូរ** អត្តលេខ ០៨០៨
៥- លោកឧត្តមសេនីយ៍ត្រី **ប្រាក់ ណារ៉ុខ** អត្តលេខ ០៤៨៩១
៦- លោកឧត្តមសេនីយ៍ត្រី **ហាឡ សុរិយា** អត្តលេខ ០៧៩៤
៧- លោកឧត្តមសេនីយ៍ត្រី **ធួន វិជ្ជល** អត្តលេខ ០៧៨៨

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

៨- លោកឧត្តមសេនីយ៍ត្រី **ញឹម ចណ្ណារ៉ា** អត្តលេខ ០៣៥២៤

៩- លោកឧត្តមសេនីយ៍ត្រី **ឆាយ សាម៉េត** អត្តលេខ ០៧៩៣

១០- លោកឧត្តមសេនីយ៍ត្រី **ទ្រី គឹមសេង** អត្តលេខ ០៧៩៧

១១- លោកឧត្តមសេនីយ៍ត្រី **នេង ពន្លក** អត្តលេខ ៣០៣៦០

១២- លោកឧត្តមសេនីយ៍ត្រី **ឆយ ឈឿង** អត្តលេខ ០៨០៧

១៣- លោកឧត្តមសេនីយ៍ត្រី **យឹម សុចណ្ណាធុន** អត្តលេខ ០៩៥៥

១៤- លោកឧត្តមសេនីយ៍ត្រី **ប៉ែន ចាន់ថុល** អត្តលេខ ០៨១៨

១៥- លោកឧត្តមសេនីយ៍ត្រី **នួន ទិឡ្យាស័ក** អត្តលេខ ០៨៥៧

១៦- លោកឧត្តមសេនីយ៍ត្រី **ម៉ែន រតនា** អត្តលេខ ០៨១១

គ- ថ្នាក់ឧត្តមសេនីយ៍ត្រី

១- លោកវរសេនីយ៍ឯក **សេន សត្យា** អត្តលេខ ០៥៨៥៤

២- លោកវរសេនីយ៍ឯក **ទ្រី ចន្ទី** អត្តលេខ ០៤៨៩២

៣- លោកវរសេនីយ៍ឯក **ទើង សុធី** អត្តលេខ ០៨៥០

៤- លោកវរសេនីយ៍ឯក **អ៊ួន សុខន** អត្តលេខ ០៤៨៩០

៥- លោកវរសេនីយ៍ឯក **ម៉ុល ចន្ថា** អត្តលេខ ០៤៨៩៧

៦- លោកវរសេនីយ៍ឯក **សេង ម៉ុនថន** អត្តលេខ ០១០៤៧

៧- លោកវរសេនីយ៍ឯក **ហាឡ្យ ធី** អត្តលេខ ០៥៨៤១

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុក អនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស/រកត/០៥១២/៤៤៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១២

លេខ: ៤០៧/ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២០១២

អគ្គលេខាធិការរងនៃរាជរដ្ឋាភិបាល

ស្រ៊ុយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៥១២/៤៤៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១.- ត្រូវបានតែងតាំង ៖

១- ឯកឧត្តម ខ្វង វីរៈ	ជា ទីប្រឹក្សារដ្ឋមន្ត្រីក្រសួងទេសចរណ៍ មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន
២- ឯកឧត្តម គង់ សុលីដា	ជា ទីប្រឹក្សារដ្ឋមន្ត្រីក្រសួងទេសចរណ៍ មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន
៣- ឯកឧត្តម ភ័ត់ ធំធើន	ជា ទីប្រឹក្សារដ្ឋមន្ត្រីក្រសួងទេសចរណ៍ មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន
៤- ឯកឧត្តម សូ វិសុទ្ធី	ជា ទីប្រឹក្សារដ្ឋមន្ត្រីក្រសួងទេសចរណ៍ មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២.- សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣.- ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣១៣៩.១២០៥.៤៤៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១២

លេខ ៤០៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១២
អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល
សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៥១២/៤៤៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជន ចំនួន ០២ រូប

មានគុណបំណាច់ និងស្នាដៃក្នុងការអភិវឌ្ឍន៍វិស័យព្រះពុទ្ធសាសនា ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងសមិទ្ធផលនានា នៅវត្តរលាំងនាគ ឃុំស្វាយជុក ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា

១- ឯកឧត្តម អ៊ុត ពញ្ញា

២- លោក ស្រី សុទ្ធា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរជ.១២០៥.៤៥០

ធ្វើនៅព្រះបរមរាជវាំង , ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១២

លេខៈ ៥១៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១២
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៥១២/៤៤៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រត្ននខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជន ចំនួន ០២ រូប

ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ដើម្បីរួមចំណែកកសាងសមិទ្ធផល

ក្នុងវិស័យវប្បធម៌ និងព្រះពុទ្ធសាសនា នៅខេត្តសៀមរាប

នូវ

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

១- លោកស្រី ទឹម សុធា

២- លោក ឡាច ធុទ្ធី

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣១ទល. ១២០៥.៤៥១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១២

លេខ: ៤១៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល
ស៊យ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៥១២/៤៤៧

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្ដិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ព្រះសង្ឃ និងសប្បុរសជន ចំនួន ០៤ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ក្នុងការចូលរួមកសាងវត្ត និងផ្ដល់សេវាសុខភាពដល់ប្រជាពលរដ្ឋ ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្ដាល

នូវ

ក. គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍**

១- ព្រះគ្រូថេរញ្ញាណោ **ម៉ែ ថាន់**

២- លោកជំទាវ **ហ្លួត សុម៉ាលី**

៣- ឯកឧត្ដម **ចេង ញ៉ាន់**

ខ. គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា**

- មហាឧបាសិកា **សុខ អ៊ីម**

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ
នរោត្ដម សីហមុនី

៣៧៩.១២០៥.៤៥២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១២

លេខ: ៤១៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការរដ្ឋាភិបាល

ស៊ឹម សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៥១២/៤៤៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានត្តមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតម្លើងថ្នាក់ ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី ជូនមន្ត្រីរាជការនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងព្រះបរមរាជវាំង គិតចាប់ពីថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១២ តទៅ ដូចខាងក្រោម ៖

១-ឯកឧត្តម	**គីម សៀ**	ពីឧត្តមមន្ត្រីថ្នាក់លេខ ៤	ទៅឧត្តមមន្ត្រីថ្នាក់លេខ ៣
២-លោកជំទាវ	**តាន់ សុខា**	ពីឧត្តមមន្ត្រីថ្នាក់លេខ ៤	ទៅឧត្តមមន្ត្រីថ្នាក់លេខ ៣
៣-ឯកឧត្តម	**ហ៊ាន់ ហ៊ាន**	ពីឧត្តមមន្ត្រីថ្នាក់លេខ ៤	ទៅឧត្តមមន្ត្រីថ្នាក់លេខ ៣
៤-ឯកឧត្តម	**មាស ពៅន**	ពីឧត្តមមន្ត្រីថ្នាក់លេខ ៤	ទៅឧត្តមមន្ត្រីថ្នាក់លេខ ៣
៥-ឯកឧត្តម	**សូ ស៊ីនួន**	ពីឧត្តមមន្ត្រីថ្នាក់លេខ ៥	ទៅឧត្តមមន្ត្រីថ្នាក់លេខ ៤
៦-ឯកឧត្តម	**ឡាត់ គី**	ពីឧត្តមមន្ត្រីថ្នាក់លេខ ៥	ទៅឧត្តមមន្ត្រីថ្នាក់លេខ ៤
៧-ឯកឧត្តម	**ម៉ែន ឌុទ្ធី**	ពីឧត្តមមន្ត្រីថ្នាក់លេខ ៥	ទៅឧត្តមមន្ត្រីថ្នាក់លេខ ៤

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ចករ
នរោត្តម សីហមុនី

តារាង. ១២០៥.៤៥៣

លេខ: ៤៧១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១២

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៥១២/៤៤៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ថ្នាក់ដឹកនាំ ចំនួន ០៣ រូប មានគុណបំណាច់ចំពោះជាតិមាតុភូមិ
ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាង និងអភិវឌ្ឍន៍ខេត្តប៉ៃលិន

នូវ

គ្រឿងឥស្សរិយយស ជាតូបការ

១- លោកជំទាវ ធាន ស្រីមុំ អ៊ីឈាន

២- ឧកញ៉ា ជា គា

៣- បណ្ឌិត ឆ បូណារី

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣ទល.១២០៥.៤៥៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១២

លេខ: ៤១៧ ច.ល
ដើម្បីចម្លងចេញ
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១២
អគ្គលេខាធិការរង[illegible]រាជរដ្ឋាភិបាល

ស៊ុយ សុខា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៧៣ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៥.៩១៤ ហិកតា
ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកសន្ទុក ខេត្តកំពង់ធំ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ
- យោងតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ស ម្រេ ច

មាត្រា១:-

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៥.៩១៤ (ប្រាំពាន់ប្រាំបួនរយដប់បួន) ហិកតា ដែលមានទីតាំងស្ថិតនៅក្នុងស្រុកសន្ទុក ខេត្តកំពង់ធំ ដើម្បីធ្វើការវិនិយោគដាំដំណាំកសិឧស្សាហកម្ម(ដាំកៅស៊ូ) ដូចមានក្នុងផែនទី និងនិយាមកាលេខ ១៤២ បជ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១២ របស់សាលាខេត្តកំពង់ធំ ជាឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

មាត្រា២:-

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល ។

មាត្រា៣:-

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៤-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួង ស្ថាប័ន និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែឧសភា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u>:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ, កាលប្បវត្តិ

ផែនទី ទីតាំងស្នើសុំសំរាប់ដាំដើមឈើ របស់ ក្រុមហ៊ុន H.M.H ខេត្តកំពង់ធំ



សញ្ញាសំគាល់

- ចំនុចគោល
- ព្រំប្រទល់តំបន់ស្រាវជ្រាវ
- ព្រំប្រទល់ដីស្នើសុំ
- ព្រំប្រទល់ឃុំ
- ផ្លូវលំ
- ផ្លូវទឹក

ផ្ទៃដីត្រូវកាត់ចេញ ១ ៧២៣ ហ.ត

គំរបព្រៃឈើឆ្នាំ ២០០២

ព្រៃល្បោះ : ៤ ហ.ត

ព្រៃជ្រុង១ : ៥ ៦៥៧ ហ.ត

ដីពុំមានគំរបព្រៃ : ២៥៣ ហ.ត

ផ្ទៃដីសម្បទាន ៥.៩១៤ ហ.ត

Scale 1 : 50,000

2Km

លេខ...	លេខ...	លេខ...	លេខ...	ភ្នំពេញថ្ងៃទី ... ខែ ... ឆ្នាំ ២០០៦
បានឃើញ និង គោរពជូន	បានឃើញនិងបញ្ជាក់ថា	បានឃើញនិងបញ្ជាក់ថា	បានឃើញនិងបញ្ជាក់ថា	ប្រធានក្រុមហ៊ុន អេច.អឹម.អេច
ថ្ងៃទី ... ខែ ... ឆ្នាំ ២០០៦	ថ្ងៃទី ... ខែ ... ឆ្នាំ ២០០៦	ថ្ងៃទី ... ខែ ០៤ ឆ្នាំ ២០០៦	ថ្ងៃទី ... ខែ ... ឆ្នាំ ២០០៦	
អភិបាលខេត្តកំពង់ធំ	អភិបាលស្រុកសន្ទុក	មេឃុំបឹង...	មេឃុំ...	
...	...	...	...	

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៨៤ . អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការដាក់ឱ្យប្រើប្រាស់នីតិវិធីរួមបច្ចុប្បន្នកម្ម សម្រាប់ការអនុវត្ត គម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកម/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨/អនក្រ/បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និង អនុក្រឹត្យលេខ២០/អនក្រ/បក ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤/អនក្រ/បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការដំឡើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សម្រេច

មាត្រា ១.-

ដាក់ឱ្យប្រើប្រាស់នីតិវិធីរួមបច្ចុប្បន្នកម្ម សម្រាប់អនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍នានា ដូចមានខ្លឹមសារភ្ជាប់មកជាមួយអនុក្រឹត្យនេះ ជំនួសនីតិវិធីរួមសម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី ដែលបានដាក់ឱ្យអនុវត្តដោយអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧។

មាត្រា ២.-

នីតិវិធីរួមបច្ចុប្បន្នកម្ម ដែលត្រូវបានដាក់ឱ្យប្រើប្រាស់ក្រោមអនុក្រឹត្យនេះ រួមមាន:

១- នីតិវិធីរួមបច្ចុប្បន្នកម្មសម្រាប់ការគ្រប់គ្រងរដ្ឋបាលគម្រោង

២- នីតិវិធីរួមបច្ចុប្បន្នកម្មសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុគម្រោង

៣- នីតិវិធីរួមបច្ចុប្បន្នកម្មសម្រាប់ការគ្រប់គ្រងកិច្ចលទ្ធកម្មគម្រោង

សម្រាប់គម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍នានានៅកម្ពុជា។

មាត្រា ៣.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៨៦ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ ជូនអង្គភាពការិយាល័យសហប្រតិបត្តិការយោធាស្ថានទូតសហរដ្ឋអាមេរិក ប្រចាំព្រះរាជាណាចក្រកម្ពុជា** ដែលបានផ្តល់ថវិកាចំនួន ១០០.០០០ ដុល្លារអាមេរិក ក្នុងការជួយកសាងអគារសិក្សា ០១ខ្នង មាន០៥បន្ទប់ បង្គន់អនាម័យ០១ខ្នង មាន០៥បន្ទប់ អណ្តូងស្នប់ ០១ និងអាងស្តុកទឹក ០១ ព្រមទាំងបំពាក់គ្រឿងសង្ហារិមគ្រប់គ្រាន់ ជូនដល់សាលាបឋមសិក្សាឈើទាល ស្ថិតនៅភូមិឈើទាល ឃុំត្នោតជុំ ស្រុកក្រគរ ខេត្តពោធិ៍សាត់ ។

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និងអភិបាលនៃគណៈអភិបាលខេត្តពោធិ៍សាត់ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា១ និងមាត្រា២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៤៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក NOZAKI SHINGO ប្រធានសហព័ន្ធប្រឹក្សា នៃ ក្រុមការងារក្រុមហ៊ុន ប៉ាណាសូនិច អេឡិចត្រូនិច នៃប្រទេសជប៉ុន ដែលបានផ្តល់ថវិកាចំនួន ៦៩.៤០០ ដុល្លារអាមេរិក ក្នុងការជួយកសាងអគារសិក្សាថ្មី ០១ខ្នង មាន០៤បន្ទប់ ព្រមទាំងបំពាក់គ្រឿងសង្ហារិមគ្រប់គ្រាន់ និងសង់បង្គន់អនាម័យ ០១ខ្នង មាន០៤បន្ទប់ ជូនដល់សាលាបឋមសិក្សាអូរជ្រៅថ្មី ស្ថិតនៅភូមិបាលិលេយ្យ២ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ។

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និងអភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៨៤ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក Mizume Takezawa សប្បុរសជនជប៉ុន ដែលបានផ្តល់ថវិកាចំនួន ៥៩.៤៧៥ ដុល្លារអាមេរិក តាមរយៈអង្គការ JHP ក្នុងការជួយកសាងអគារសិក្សា ០១ខ្នង មាន ០៥បន្ទប់ បង្គន់អនាម័យ ០១ខ្នង មាន០៥បន្ទប់ សង់អំពីបេតុង ព្រមទាំងបំពាក់គ្រឿងសង្ហារិមគ្រប់គ្រាន់ និងអណ្តូងស្នប់ ជូនដល់អនុវិទ្យាល័យរស្មីកុមារ ស្ថិតនៅភូមិស្វាយលិច សង្កាត់សួង ក្រុងសួង ខេត្តកំពង់ចាម ។

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ឧសភា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៥៧៩ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន០៧គ្រឿង ជូនសប្បុរសជន សមាគម និងក្រុមហ៊ុនទេសចរណ៍ ដែលបានផ្តល់ថវិកាសរុបចំនួន ២៤៤.០០០ ដុល្លារអាមេរិក ក្នុងការជួយកសាងអគារមណ្ឌលសុខភាព ០១ខ្នង ២ជាន់ មាន១៤បន្ទប់ អគារផ្ទាល់ដី សម្រាប់ការិយាល័យ ០១បន្ទប់ និងបានកសាងផ្លូវមួយខ្សែ ចូលទៅមណ្ឌល**អន្តរាគ្គីសង្ឃឹមថ្មី** ស្ថិតនៅខេត្តសៀមរាប ដូចមានរាយនាមខាងក្រោម ៖

១-លោក Ryan Geoffrey Schell
២-សមាគម Rotary Club of Ashmore Initiator of Rotary Australia World Community Service New Hope Project
៣-សមាគម Pink Umbrella Foundation
៤-សាកលវិទ្យាល័យ Medical Centre Utrecht ប្រទេសហូឡង់
៥-ក្រុមហ៊ុនទេសចរណ៍ Travel Company Planeterra Foundation & G Adventures
៦- ក្រុមហ៊ុនទេសចរណ៍ Travel Company Make my day Better
៧-លោក Ron Carter **សប្បុរសជន**

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និងអភិបាលនៃគណៈអភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ... ខែ ឧសភា ឆ្នាំ ២០១២
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៤៩០ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងព័ត៌មាន

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយមុនីសារាភ័ណ្ឌ តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ចំនួន០៥រូប នៃមន្ទីរព័ត៌មានខេត្តប៉ៃលិននិងខេត្តបន្ទាយមានជ័យ ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចជូនជាតិមាតុភូមិជាច្រើនឆ្នាំកន្លងមកលើវិស័យព័ត៌មាន ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ:

-លោក គង់ ជួន ប្រធានមន្ទីរព័ត៌មាន ខេត្តប៉ៃលិន

ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ:

១-លោក ឌុំ សុខ អនុប្រធានមន្ទីរព័ត៌មាន ខេត្តប៉ៃលិន
២-លោក គង ឆ្លូក អនុប្រធានមន្ទីរព័ត៌មាន ខេត្តប៉ៃលិន
៣-លោក គង់ ជី ប្រធានការិយាល័យមន្ទីរព័ត៌មាន ខេត្តប៉ៃលិន
៤-លោក ចក់ កុសល អនុប្រធានមន្ទីរព័ត៌មានខេត្តបន្ទាយមានជ័យ

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១២
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ..៥៩១..អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងព័ត៌មាន

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ចំនួន២៣រូប នៃមន្ទីរព័ត៌មានខេត្តប៉ៃលិន និងខេត្តបន្ទាយមានជ័យ ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចជូនជាតិមាតុភូមិជាច្រើនឆ្នាំកន្លងមកលើវិស័យព័ត៌មាន ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយមាសការងារៈ

១-លោក គង់	ម៉ុនធីម	ប្រធានការិយាល័យ មន្ទីរព័ត៌មានខេត្តប៉ៃលិន
២-លោក ទូច	ពឿន	អនុប្រធានការិយាល័យ មន្ទីរព័ត៌មានខេត្តប៉ៃលិន
៣-លោក ម៉ាត់	ចំនួសុខា	មន្ត្រី នៃមន្ទីរព័ត៌មានខេត្តប៉ៃលិន
៤-លោក ញ៉ឹប	បូរី	មន្ត្រី នៃមន្ទីរព័ត៌មានខេត្តប៉ៃលិន
៥-លោកស្រីឈ្មួន	ធវី	មន្ត្រី នៃមន្ទីរព័ត៌មានខេត្តប៉ៃលិន
៦-លោក សំ	កុសល	អនុប្រធានការិយាល័យវិទ្យុជាតិ
៧-លោក សែប	អារុណា	មន្ត្រី នៃមន្ទីរព័ត៌មានខេត្តបន្ទាយមានជ័យ
៨-លោក លី	ប៊ុណ្ណារិទ្ធ	អនុប្រធានការិយាល័យ នៃមន្ទីរព័ត៌មានខេត្តប៉ៃលិន

ខ-មេដាយប្រាក់ការងារៈ

១-លោកស្រី ទូច	ដេម	មន្ត្រី នៃមន្ទីរព័ត៌មានខេត្តប៉ៃលិន
២-លោកស្រី ខាត់	សុខា	មន្ត្រី នៃមន្ទីរព័ត៌មានខេត្តប៉ៃលិន
៣-លោកស្រី ធី	នី	មន្ត្រី នៃមន្ទីរព័ត៌មានខេត្តប៉ៃលិន
៤-លោកស្រី ពេជ្រ	ចំនួរស្មី	មន្ត្រី នៃមន្ទីរព័ត៌មានខេត្តប៉ៃលិន

៥-លោក	នី យ៉ាន់ឌី	មន្ត្រី នៃមន្ទីរព័ត៌មានខេត្តប៉ៃលិន
៦-លោក	ចិក ម៉ៅ	អនុប្រធានការិយាល័យ នៃមន្ទីរព័ត៌មានខេត្តបន្ទាយមានជ័យ
៧-លោក	ហ៊ី សារឿន	អនុប្រធានការិយាល័យ នៃមន្ទីរព័ត៌មានខេត្តបន្ទាយមានជ័យ
៨-លោក	ឡៅ សំពរ	ប្រធានការិយាល័យ នៃមន្ទីរព័ត៌មានខេត្តបន្ទាយមានជ័យ
៩-លោក	រីវ សារឿត	អនុប្រធានការិយាល័យ នៃមន្ទីរព័ត៌មានខេត្តបន្ទាយមានជ័យ
១០-លោក	ឌី ម៉េង	ប្រធានការិយាល័យ នៃមន្ទីរព័ត៌មានខេត្តបន្ទាយមានជ័យ
១១-លោកស្រី	ឆឹយ តែ	ប្រធានការិយាល័យ នៃមន្ទីរព័ត៌មានខេត្តបន្ទាយមានជ័យ
១២-លោក	ឌុល សុវណ្ណា	មន្ត្រី នៃមន្ទីរព័ត៌មានខេត្តបន្ទាយមានជ័យ
១៣-លោក	សុន ខ្លី	ប្រធានការិយាល័យ នៃមន្ទីរព័ត៌មានខេត្តបន្ទាយមានជ័យ
១៤-លោក	ហាក់ ចិន្តា	ប្រធានការិយាល័យ នៃមន្ទីរព័ត៌មានខេត្តបន្ទាយមានជ័យ
១៥-លោកស្រី	អ៊ូ សុផានី	អនុប្រធានការិយាល័យ នៃមន្ទីរព័ត៌មានខេត្តបន្ទាយមានជ័យ

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ ឧសភា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៩៧.អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការតែងតាំងមុខងារ នាយទាហាន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
